# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ០១ នក.៥៦៦-៨៥

## <u>សារាចរ</u>

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## <u>ផ្ញើចំពោះ</u>

**សមមិត្តប្រធានតុលាការប្រជាជន ខេត្ត ក្រុង**

**សមមិត្តរដ្ឋអាជ្ញាអមតុលាការប្រជាជន ខេត្ត ក្រុង**

**<u>កម្មវត្ថុ</u>:** សេចក្តីណែនាំអំពីរបៀបចាត់ការ និងនីតិវិធីសម្រាប់អយ្យការ និងតុលាការប្រជាជនខេត្ត ក្រុង

ដើម្បីជៀសវាងការភ័ន្តច្រឡំ ការបកស្រាយមិនឯកភាពគ្នាក្នុងការប្រើពាក្យ សម្រេចលើកលែងចោទប្រកាន់ និង សម្រេចមិនចោទប្រកាន់ជនប្រព្រឹត្តបទល្មើស ដែលមានចែងក្នុងសារាចរណែនាំលេខ ១០៤៨ ក.យ.ធ ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ១៩៨២ របស់ក្រសួងយុត្តិធម៌ និងដើម្បីអោយតុលាការដំណើរការ ជំនុំជម្រះបានត្រឹមត្រូវនូវរឿងព្រហ្មទណ្ឌ ដែលមានជនប្រព្រឹត្តបទល្មើសជាអនីតិជន និងជាជនវិកលចរិតក្រសួងយុត្តធម៌មានកាតព្វកិច្ចធ្វើសេចក្តីណែនាំដូចតទៅ៖

I-**អំពីសេចក្តីសម្រេចពីការចោទប្រកាន់ ឬ មិនចោទប្រកាន់ជនប្រព្រឹត្តបទល្មើស**

អំណឹះតទៅ រដ្ឋអជ្ញាអមតុលាការប្រជាជនទូទាំងប្រទេស ត្រូវអនុវត្តឲ្យបានសមស្របតាមចំណុច ២ មាត្រា ៣ នៃច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ និងអយ្យការ ។ រដ្ឋអាជ្ញាត្រូវអនុវត្តលក្ខការណ៍ដូចខាងក្រោម៖

១-សម្រេចពីការចោទប្រកាន់ជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ក្នុងករណីដែលរដ្ឋអាជ្ញាយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់អំពើល្មើសនាំមកនូវគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គម ធ្វើអោយប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ។

២-សម្រេចពីការមិនចោទប្រកាន់ជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ករណីដែលរដ្ឋអាជ្ញាយល់ឃើញថា៖

ក-ពិរុទ្ធភាពមិនគ្រប់គ្រាន់លើជនប្រព្រឹត្តបទល្មើស

ខ-រឿងមានប្រភេទជារដ្ឋប្បវេណី

គ-បទល្មើសព្រហ្មទណ្ឌមានលក្ខណៈតូចតាច ពុំបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គម មិនធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ

ឃ-ជនប្រព្រឹត្តបទល្មើសជាជនវិកលចរិត

ង-ជនប្រព្រឹត្តបទល្មើសជាអនីតិជនអាយុតិចជាង ១៤ ឆ្នាំ ។

ចំពោះករណីដែលចែងក្នុងចំណុច ក.ខ.គ. រដ្ឋអាជ្ញាត្រូវអនុវត្តតាមសារាចរណែនាំលេខ ១០៤៨ ក.យ.ធ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៨២ របស់ក្រសួងយុត្តិធម៌ ប៉ុន្តែក្នុងករណីទាំង ៣នេះ ត្រូវប្រើពាក្យសម្រេចពីការមិនចោទប្រកាន់ ។

ចំពោះជនប្រព្រឹត្តបទល្មើសដែលចែងក្នុងចំណុច ឃ.ង ក្រោយពីការសម្រេចមិនចោទប្រកាន់រដ្ឋអាជ្ញាត្រូវបញ្ជូនសំណុំរឿងទៅតុលាការប្រជាជនផ្នែកព្រហ្មទណ្ឌ ដើម្បីសម្រេចអំពីសំណងរដ្ឋប្បវេណី ដែលអ្នកទទួលខុសត្រូវលើជនប្រព្រឹត្តបទល្មើសត្រូវសងទៅដើមបណ្តឹង ។ ក្នុងលិខិតបញ្ជូនសំណុំរឿង រដ្ឋអាជ្ញាត្រូវបញ្ជាក់ពីពិរុទ្ធភាពនិង

ករណីមិនយកទោសព្រហ្មទណ្ឌមកអនុវត្ត ព្រមទាំងបញ្ជាក់អំពីអ្នកទទួលខុសត្រូវអោយ បានច្បាស់លាស់ ។

## II-**អំពីនីតិវិធីជំនុំជម្រះ របស់តុលាការប្រជាជនផ្នែកព្រហ្មទណ្ឌ ចំពោះរឿងដែលមានជនប្រព្រឹត្តបទល្មើស ជាអនីតិជន និងជនវិកលចរិត**

តុលាការប្រជាជនផ្នែកព្រហ្មទណ្ឌ ត្រូវអនុវត្តលក្ខការណ៍ដូចតទៅ

១-ចំពោះជនប្រព្រឹត្តបទល្មើសជាអនីតិជនអាយុតិចជាង ១៤ ឆ្នាំ ក៏ដូចជាអនីតិជនអាយុពី ១៤ ឆ្នាំ ទៅ ១៨ ឆ្នាំ តុលាការប្រជាជនផ្នែកព្រហ្មទណ្ឌ នៅពេលសវនាការត្រូវធ្វើការសួរដេញដោលជាសម្ងាត់ ។

២-នៅគ្រប់រឿងដែលមានជនជាប់ចោទជាអនីតិជន ឬជាជនវិកលចរិត តុលាការប្រជាជនត្រូវចាត់តាំងដោយឯកឯងនូវមេធាវី ឬអ្នកការពារសិទ្ធិម្នាក់អោយជួយការពារជនជាប់ចោទ បើជនជាប់ចោទគ្មានលទ្ធភាពនឹងពឹងអ្នកកាពារសិទ្ធិឲ្យជួយការពារខ្លួនបាន ។

៣-ចំពោះជនអាយុតិចជាង១៤ឆ្នាំ និងជនវិកលចរិកដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានរដ្ឋអាជ្ញាសម្រេចមិនចោទប្រកាន់ តុលាការប្រជាជនផ្នែកព្រហ្មទណ្ឌត្រូវយកចិត្តទុកដាក់ពិនិត្យអោយបានហ្មត់ចត់អំពីពិរុទ្ធភាព ព្រមទាំងវាយតម្លៃអោយបានត្រឹមត្រូវនូវទំហំដែលបានខូចខាតបណ្តាលមកពីអំពើល្មើស មុននឹងឈានចូលដល់ការសម្រេចសំណងរដ្ឋប្បវេណី ។

## III-**កំណត់សម្គាល់**

ក្នុងរឿងព្រហ្មទណ្ឌ មានករណី២ទៀត ដែលប្រព្រឹត្តបទល្មើសត្រូវបានចាកផុតពីការផ្តន្ទាទោសព្រហ្មទណ្ឌ ប៉ុន្តែត្រូវទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី ហើយការសម្រេចអំពីសំណងរដ្ឋប្បវេណីក៏ជាសមត្ថកិច្ចរបស់តុលាការប្រជាជនផ្នែកព្រហ្មទណ្ឌដែរ ។ ករណីទាំង ២ នោះ គឺ

-ករណីជនប្រព្រឹត្តបទល្មើសទទួលមរណភាពមុនពេលជំនុំជម្រះ

-ករណីជនប្រព្រឹត្តបទល្មើសត្រូវបានទទួលការលើកលែងទោសជាទូទៅ

ក្នុងករណីទាំង ២ ខាងលើ បើនៅក្នុងសំណុំរឿងមានដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទារសំណងជួសជុលការខូចខាតរដ្ឋអាជ្ញាត្រូវពិនិត្យមើលពិរុទ្ធភាពលើជនប្រព្រឹត្តបទល្មើសជាមុនសិន មុននឹងសម្រេចបញ្ជូនសំណុំរឿងទៅតុលាការប្រជាជនផ្នែកព្រហ្មទណ្ឌ ដើម្បីជំនុំជម្រះអំពីសំណងរដ្ឋប្បវេណី ។

តុលាការប្រជាជនផ្នែកព្រហ្មទណ្ឌ ក៏ត្រូវសម្រេចអំពីពិរុទ្ធភាពដែរ មុននឹងឈានចូលដល់ការសម្រេចអំពីសំណងរដ្ឋប្បវេណី ។

ក្រសួងយុត្តិធម៌ សូមទាញអារម្មណ៍ដល់អយ្យការ និងតុលាការប្រជាជន ទូទាំងប្រទេសអោយយកចិត្តទុកដាក់អនុវត្តតាមសារាចរនេះអោយបានត្រឹមត្រូវបំផុត ព្រមទាំងបញ្ជាក់ថា សារាចរលេខ១០៤៨ ក.យ.ធ ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ១៩៨២ ស្ថិតនៅជាធរមានលើកលែងពាក្យ សម្រេចលើកលែងការចោទប្រកាន់ដែលត្រូវយកពាក្យសម្រេចមិនចោទប្រកាន់ មកជំនួសវិញ ។

ក្រសួងយុត្តិធម៌សង្ឃឹមថា សេចក្តីណែនាំនេះបានជាបង្អែកក្នុងចំណាត់ការរបស់អយ្យការ និង តុលាការប្រជាជន ដើម្បីពង្រឹងនីត្យានុកូលភាព ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៨៥

**ហត្ថលេខា និងត្រា**

**អ៊ុត ប៊ុនឈឿន**